# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ

**២០១៦-២០១៧**

| **សំណួរដែលគេឧស្សាហ៍សួរអំពីថ្នាក់មុនមត្តេយ្យ** | |
|---|---|
| **សំណួរ** | **ចម្លើយ** |
| ***តើអស់ថ្លៃប៉ុន្មាន?*** | ឥតបង់ប្រាក់។ |
| ***ថ្ងៃណាខ្លះ និង ម៉ោងប៉ុន្មាន?*** | ម៉ោងអាចខុសៗគ្នា នៅតាមទីកន្លែងនីមួយៗ ប៉ុន្តែម៉ោងជាទូទៅគឺ៖<br>ថ្ងៃច័ន្ទ ដល់ ថ្ងៃព្រហស្បតិ៍ ពីម៉ោង ៨:៣០ ព្រឹក ដល់ ៣:០០ រសៀល<br>ថ្ងៃសុក្រ ពីម៉ោង ៨:៣០ ព្រឹក ដល់ ១២:៣០ រសៀល |
| ***តើគេផ្តល់អាហារថ្ងៃត្រង់ឲ្យកូនខ្ញុំដែរឬទេ?*** | គេនឹងផ្តល់ អាហារពេលព្រឹក អាហារថ្ងៃត្រង់ និង ចំណីនៅថ្ងៃរសៀល ដល់កូនលោកអ្នកដោយឥតគិតថ្លៃពីលោកអ្នក។ សេវានេះឧបត្ថម្ភដោយ កម្មវិធីម្ហូបអាហារសម្រាប់ កុមារ និង មនុស្សពេញវ័យ។ |
| ***តើមានសេវាថយន្តសាលាដែរឬទេ?*** | សេវាយានជំនិះតាមរយៈក្រសួងអប់រំ មិនផ្តល់ឲ្យកុមារមុនថ្នាក់មត្តេយ្យទេ។ |
| ***តើខ្ញុំអាចទៅជួបគ្រូរបស់កូនខ្ញុំ និង ទៅមើលថ្នាក់រៀនរបស់ពួកគេ មុនថ្ងៃចូលរៀនដំបូងបានដែរឬទេ?*** | បាន មាតាបិតារបស់កុមារដែលចុះឈ្មោះចូលរៀនថ្មី នឹងមានឱកាសនេះ នៅពេលជួបប្រជុំសម្រាប់ការណែនាំ ដែលណាត់ពេលជួបគ្នារវាង មាតាបិតា និង គ្រូ។ |
| ***តើមាតាបិតាត្រូវបំពេញ លិខិតដាក់ពាក្យសុំចូលរៀនថ្នាក់មុនមត្តេយ្យថ្មី ឬទេ បើសិនជាកុមារត្រឡប់មកចូលរួមក្នុងកម្មវិធីនេះ នៅឆ្នាំទី២?*** | មិនបាច់ទេ មាតាបិតាមិនចាំបាច់បំពេញលិខិតដាក់ពាក្យសុំចូលរៀនថ្មីទេ។ ចំពោះសិស្សនៅក្នុងកម្មវិធី Head Start និង Bright Futures គេតម្រូវឲ្យមាន ការពិនិត្យសុខភាព ការពិនិត្យធ្មេញ និង ការចាក់ថ្នាំបង្ការរោគ ថ្មីៗ។ ជាបន្ថែមទៀត ចំពោះសិស្សនៅក្នុងកម្មវិធី Bright Futures ក៏ត្រូវការលិខិតសម្រាប់ កម្មវិធីម្ហូបអាហារសម្រាប់ កុមារ និង មនុស្សពេញវ័យ ថ្មីផងដែរ។ |
| ***តើកុមារមុនថ្នាក់មត្តេយ្យ មានអាយុប៉ុន្មានឆ្នាំ?*** | កុមារត្រូវមានអាយុយ៉ាងហោចណាស់៣ឆ្នាំ នៅថ្ងៃ ឬមុនថ្ងៃ ទី១ ខែកញ្ញា នៃឆ្នាំដែលពួកគេចង់ចុះឈ្មោះរៀននៅក្នុងកម្មវិធីមុនថ្នាក់មត្តេយ្យ។ បើសិនជាកុមារមានអាយុ៥ឆ្នាំ នៅថ្ងៃ ឬមុនថ្ងៃ ទី១ ខែកញ្ញា ពួកគេត្រូវចុះឈ្មោះរៀននៅក្នុងថ្នាក់មត្តេយ្យ។ បើសិនជាកុមារមានអាយុ៥ឆ្នាំ នៅថ្ងៃ ឬក្រោយថ្ងៃ ទី២ ខែកញ្ញា ពួកគេមានអាយុអាចចូលរៀនថ្នាក់មុនមត្តេយ្យ។ |
| ***តើខ្ញុំអាចចុះឈ្មោះកូនដោយវិធីណា?*** | ដើម្បីចុះឈ្មោះកូនឲ្យចូលរៀន លោកអ្នកត្រូវបំពេញ លិខិតដាក់ពាក្យសុំចូលរៀនថ្នាក់មុនមត្តេយ្យ និងផ្តល់ឯកសារដែលគេត្រូវការទាំងអស់។ ព័ត៌មានលម្អិតមាននៅក្នុងលិខិតដាក់ពាក្យសុំចូលរៀន។ លិខិតដាក់ពាក្យសុំចូលរៀន មាននៅទីកន្លែងថ្នាក់មុនមត្តេយ្យ នៅក្នុងវ៉ិបសៃរបស់ក្រសួងអប់រំ https://webapps.philasd.org/stor/Preschool_Registration_Flyer_Khmer_Combo.pdf ឬដោយទូរស័ព្ទទៅលេខ ២១៥-៤០០-៤២៧០ ហើយធ្វើតាមសម្លេងណែនាំ ដើម្បីស្នើសុំឲ្យគេផ្ញើ លិខិតដាក់ពាក្យសុំចូលរៀន ទៅឲ្យលោកអ្នក។ លិខិតដាក់ពាក្យសុំចូលរៀនថ្នាក់មុនមត្តេយ្យទាំងអស់ ត្រូវដាក់ពាក្យនៅ អាស័យដ្ឋានលេខ 440 N. Broad St., បន្ទប់លេខ ១៧០។ គេទទួល លិខិតដាក់ពាក្យសុំចូលរៀន ពីដើមដល់ចុងឆ្នាំ។ |
| ***តើតម្រូវឲ្យស្លៀកពាក់ឯកសណ្ឋាន ដែរឬទេ?*** | ឯកសណ្ឋានមិនមែនជាតម្រូវការចាំបាច់សម្រាប់ថ្នាក់មុនមត្តេយ្យទេ។ ទោះជាដូច្នេះក៏ដោយ នាយកសាលាខ្លះ តម្រូវឲ្យកុមារមុនថ្នាក់មត្តេយ្យស្លៀកពាក់ឯកសណ្ឋានពណ៌របស់សាលា។ គេនឹងពិភាក្សាព័ត៌មានអំពីឯកសណ្ឋាន នៅពេលជួបប្រជុំសម្រាប់ការណែនាំមាតាបិតា។ |

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្យ៉ា

ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ

| សំណួរដែលគេខ្ញុំសួរអំពីថ្នាក់មុនមត្តេយ្យ | |
|---|---|
| **សំណួរ** | **ចម្លើយ** |
| ***តើខ្ញុំអាចចុះឈ្មោះកូនរបស់ខ្ញុំនៅឯ មជ្ឈមណ្ឌលអប់រំ នៅអាស័យដ្ឋានលេខ 440 N. Broad St. បានដែរឬទេ?*** | បាន សូមយក៖ សំបុត្រកំណើតរបស់កូនលោកអ្នក សំណុំឯកសារ ចាក់ថ្នាំបង្ការរោគ ឬ ការវាយតម្លៃសុខភាព របស់កូនលោកអ្នក ប័ណ្ណធានារ៉ាប់រងសុខភាពរបស់កូនលោកអ្នក ភស្តុតាងនៃប្រាក់ចំណូលដែលបានពីការងារមុនដកពន្ធ និង ប្រាក់ក្រៅពីការងារ នាពេលបច្ចុប្បន្ន របស់ក្រុមគ្រួសារលោកអ្នក ភស្តុតាងនៃអាស័យដ្ឋានបច្ចុប្បន្នរបស់លោកអ្នក អត្តសញ្ញាណប័ណ្ណរបស់លោកអ្នក។ គេនឹងស្នើសុំឲ្យលោកអ្នកចូលរួមក្នុងការធ្វើសម្ភាសន៍ផងដែរ។ |
| ***តើពេលណាទើបខ្ញុំដឹង បើសិនជាគេទទួលកូនរបស់ខ្ញុំឲ្យចូលរៀនក្នុងកម្មវិធីនេះ?*** | គេនឹងធ្វើ លិខិតទទួលក្មេងឲ្យចូលរៀន និង លិខិតនៃបញ្ជីរង់ចាំ ក្នុងកំឡុងពេលបួន (៤) សប្តាហ៍ បន្ទាប់ពីការដាក់ពាក្យសុំចូលរៀន។ |
| ***ខ្ញុំបានបំពេញ លិខិតដាក់ពាក្យសុំចូលរៀន ឲ្យកូនខ្ញុំ ប៉ុន្តែមិនទាន់បានទទួល លិខិតទទួលក្មេងឲ្យចូលរៀន ឬ លិខិតនៃបញ្ជីរង់ចាំ នៅឡើយ។*** | មាតាបិតាអាចទូរស័ព្ទទៅលេខ ២១៥-៤០០-៤២៧០ ហើយធ្វើតាមសម្លេងណែនាំ ដើម្បីទទួលជំនួយ |
| ***តើកូនខ្ញុំអាចមានឈ្មោះនៅក្នុងបញ្ជីរង់ចាំ យូរប៉ុណ្ណា?*** | ក្មេងអាចមានឈ្មោះនៅក្នុងបញ្ជីរង់ចាំពេញមួយឆ្នាំសិក្សា។ ការទទួលក្មេងពីបញ្ជីរង់ចាំឲ្យចូលរៀនថ្នាក់មុនមត្តេយ្យ គឺយោងទៅលើការចាកចេញរបស់ក្មេងផ្សេងទៀតពីកម្មវិធីមុនថ្នាក់មត្តេយ្យ នៅកន្លែងនោះ។ នៅពេលណាមានកន្លែងទំនេរ គេនឹងទូរស័ព្ទទៅក្រុមគ្រួសារដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីរង់ចាំសម្រាប់កន្លែងនោះ។ |
| ***តើតម្រូវការសម្រាប់សិទ្ធិចូលរួមមានអ្វីខ្លះ?*** | ក្មេងត្រូវមានអាយុតាមតម្រូវការខាងលើនេះ ត្រូវរស់នៅក្នុងទីក្រុងហ្វីឡាដែលហ្យ៉ា នៃរដ្ឋធិនស៊ីលវេនញ៉ា ហើយក្រុមគ្រួសារត្រូវមានប្រាក់ចំណូលដែលត្រូវតាមសិទ្ធិនៃការចូលរួម។<br>សម្រាប់ កម្មវិធី Head Start៖ សូមមើល ប្រាក់ចំណូលកម្រិតអ្នកក្រីក្រនៃកម្មវិធី Head Start របស់រដ្ឋសហព័ន្ធ ឆ្នាំ២០១៦ តាមទំហំគ្រួសារ ដូចមានខាងក្រោមនេះ។<br>សម្រាប់ កម្មវិធី Bright Futures៖ ប្រាក់ចំណូលមុនពេលដកពន្ធប្រចាំឆ្នាំរបស់ក្រុមគ្រួសារ មិនអាចលើសពី ៣០០% នៃ ប្រាក់ចំណូលកម្រិតអ្នកក្រីក្រ ឆ្នាំ២០១៦ តាមទំហំគ្រួសាររបស់ពួកគេ បានទេ។ |

| **ប្រាក់ចំណូលកម្រិតអ្នកក្រីក្រឆ្នាំ ២០១៦ សម្រាប់៤៨រដ្ឋ និង ឌីស៊ី/D.C. ប្រាក់ចំណូលខ្ពស់បំផុតសម្រាប់ចូលរួមក្នុងកម្មវិធី Head Start** | | **៣០០% នៃប្រាក់ចំណូលកម្រិតអ្នកក្រីក្រឆ្នាំ ២០១៦ ប្រាក់ចំណូលខ្ពស់បំផុតសម្រាប់ការចូលរួមក្នុងកម្មវិធី Bright Futures Pre-K Counts** | |
|---|---|---|---|
| **ទំហំគ្រួសារ** | **ប្រាក់ចំណូលកម្រិតអ្នកក្រីក្រ** | **ទំហំគ្រួសារ** | **៣០០% នៃប្រាក់ចំណូលកម្រិតអ្នកក្រីក្រ** |
| ១ នាក់ | ១១.៨៨០$ | ១ នាក់ | ៣៥.៦៤០$ |
| ២ នាក់ | ១៦.០២០$ | ២ នាក់ | ៤៨.០៦០$ |
| ៣ នាក់ | ២០.១៦០$ | ៣ នាក់ | ៦០.៤៨០$ |
| ៤ នាក់ | ២៤.៣០០$ | ៤ នាក់ | ៧២.៩០០$ |
| ៥ នាក់ | ២៨.៤៤០$ | ៥ នាក់ | ៨៥.៣២០$ |
| ៦ នាក់ | $32,580 | ៦ នាក់ | ៩៧.៧៤០$ |
| ៧ នាក់ ឡើងទៅ | បូក ៤.១៦០$ សម្រាប់មនុស្សម្នាក់ៗ។ | ៧ នាក់ ឡើងទៅ | បូក ១២.៤៨០$ សម្រាប់មនុស្សម្នាក់ៗ។ |

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា៉

## ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ

| សំណួរដែលគេខ្វស្សាសួរអំពីថ្នាក់មុនមត្តេយ្យ | | | | |
|---|---|---|---|---|
| **សំណួរ** | **ចម្លើយ** | | | |
| *តើខ្ញុំអាចទាក់ទងអ្នកណា សម្រាប់ការបម្រើផ្សេងៗ?* | **សូមទាក់ទងអ្នកតំណាងទាំងនេះ នៅការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ** | | | |
| | Susan Maraschiello | កម្មវិធី Bright Futures | smaraschiello@philasd.org | ២១៥-៤០០-៥៧៥៧ |
| | Abigail McMahon | កម្មវិធី Head Start | amcmahon2@philasd.org | ២១៥-៤០០-៤២៧០ |
| | Lawanna Lockhart | កម្មវិធី Head Start | lbullock@philasd.org | ២១៥-៤០០-៤២៧០ |

| សំណួរដែលគេខ្វស្សាសួរអំពីថ្នាក់មត្តេយ្យ | |
|---|---|
| **សំណួរ** | **ចម្លើយ** |
| *តើថ្ងៃចូលរៀនដំបូងសម្រាប់ក្មេងថ្នាក់មត្តេយ្យ នៅថ្ងៃណា?* | ថ្ងៃចូលរៀនដំបូងសម្រាប់សិស្សថ្នាក់មត្តេយ្យ គឺមួយសប្តាហ៍ក្រោយសិស្សរបស់ក្រសួងអប់រំទាំងអស់។ នៅសប្តាហ៍នោះ គ្រូនឹងជួបជាមួយក្រុមគ្រូសារដើម្បី ធ្វើការណែនាំ/ធ្វើសម្ភាស និង បំពេញការធ្វើសម្ភាសន៍អំពីបទពិសោធន៍នៃកម្មវិធីអប់រំកុមារថ្នាក់មត្តេយ្យ។ គ្រូនៅសាលាដែលសិស្សថ្នាក់មត្តេយ្យបានចុះឈ្មោះនឹងទូរស័ព្ទទៅមាតាបិតាដើម្បីកំណត់ថ្ងៃធ្វើសម្ភាស។ សូមមើលប្រតិទិនរបស់ក្រសួងអប់រំ ដើម្បីជ្រាបពីថ្ងៃខែពិតប្រាកដ នៅក្នុងវ៊ុបសៃ www.philasd.org/language/khmer/calendar។ |
| *តើក្រុមគ្រូសារទៅជាក់ពាក្យសុំចូលរៀនថ្នាក់មត្តេយ្យ នៅទីណា?* | ជាទូទៅ សិស្សចុះឈ្មោះនៅសាលាដែលស្ថិតនៅក្នុងព្រំដែននៃតំបន់រស់នៅស្របច្បាប់របស់មាតាបិតា ឬ អាណាព្យាបាល។ មាតាបិតា/អាណាព្យាបាល ទៅសាលាក្នុងតំបន់របស់ពួកគាត់ ដើម្បីចុះឈ្មោះកូនរបស់គាត់។ មាតាបិតាអាចទូរស័ព្ទទៅលេខ ២១៥-៤០០-៤២៩០ ដើម្បីស្វែងយល់ថាតើសាលាមួយណាជាសាលាដែលស្ថិតនៅក្នុងតំបន់របស់ពួកគាត់ ឬ មើលក្នុង «ស្វែងរកសាលា/School Finder នៅក្នុងវ៊ុបសៃ www.philasd.org/school_finder/km។ |
| *តើកូនខ្ញុំត្រូវមានអាយុប៉ុន្មាន ទើបអាចចូលរៀនថ្នាក់មត្តេយ្យបាន?* | ក្មេងត្រូវមានអាយុ៥ឆ្នាំ នៅថ្ងៃទី១ ខែកញ្ញា នៃឆ្នាំដែលពួកគេចង់ចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យ។ បើសិនជាក្មេងមានអាយុ៥ឆ្នាំ នៅថ្ងៃទី២ ខែកញ្ញា ពួកគេត្រូវតែចុះឈ្មោះក្នុងកម្មវិធីថ្នាក់មុនមត្តេយ្យ។ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា៉ មិនឲ្យសិស្សប្រឡង ដើម្បីឲ្យឆាប់បានចូលរៀនថ្នាក់មត្តេយ្យទេ ទោះបីជានៅក្នុងកាលៈទេសៈណាក៏ដោយ។ |
| *តើតម្រូវការនៃសិទ្ធិចូលរួមក្នុងថ្នាក់មត្តេយ្យមានអ្វីខ្លះ?* | ក្មេងត្រូវតែមានអាយុ៥ឆ្នាំ នៅថ្ងៃទី១ ខែកញ្ញា តាមតម្រូវការ នៃឆ្នាំដែលពួកគេចង់ចុះឈ្មោះចូលរៀន។ |
| *តើខ្ញុំអាចចុះឈ្មោះកូនឲ្យចូលរៀនថ្នាក់មត្តេយ្យ ដោយវិធីណា?* | សូមទៅកាន់សាលាដែលនៅក្នុងតំបន់របស់លោកអ្នក។ សូមយកអ្វីៗទាំងនេះទៅជាមួយ៖<br>A. ***ឯកសារបញ្ជាក់ពីថ្ងៃកំណើតរបស់ក្មេង (ត្រូវការឯកសារមួយ ក្នុងចំណោមឯកសារទាំងនេះ)***<br>• ច្បាប់ដើមនៃសំបុត្រកំណើតរបស់ក្មេង<br>• ច្បាប់ចម្លងនៃសំបុត្រកំណើតរបស់ក្មេង ដែលមានបោះត្រាបញ្ជាក់<br>• លិខិតឆ្លងដែនរបស់ក្មេង ដែលមានសុពលភាព<br>• ច្បាប់ដើមនៃសំបុត្រលាងបាប ដែលបញ្ជាក់ពីថ្ងៃកំណើតរបស់ក្មេង<br>• ច្បាប់ចម្លងនៃសំបុត្រលាងបាប – ត្រូវមានបោះត្រា ឬមានការបញ្ជាក់ត្រឹមត្រូវ និងបង្ហាញពីថ្ងៃកំណើត<br>• សំណុំឯកសារសាលាពីមុន ដែលបង្ហាញពីថ្ងៃកំណើត<br>B. *ឯកសារចាក់ថ្នាំបង្ការរោគ**ថ្មីៗ របស់ក្មេង***<br>C. *អត្តសញ្ញាណប័ណ្ណរបស់ មាតាបិតា/អាណាព្យាបាល **(ត្រូវការឯកសារមួយ ក្នុងចំណោមឯកសារ ទាំងនេះ)*** |

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ

| សំណួរដែលគេខ្វល់ស្សាសួរអំពីថ្នាក់មត្តេយ្យ | |
|---|---|
| **សំណួរ** | **ចម្លើយ** |
| | • ប័ណ្ណបើកបរថ្មីៗ/អត្តសញ្ញាណប័ណ្ណមិនមែនសម្រាប់បើកបរ<br>• ប័ណ្ណធ្វើការនៅ រដ្ឋសហព័ន្ធ រដ្ឋ ឬទីក្រុង<br>• លិខិតឆ្លងដែន<br>***D. ឯកសារបញ្ជាក់ពីអាស័យដ្ឋាន (ត្រូវការឯកសារពីរ ក្នុងចំណោមឯកសារទាំងនេះ)***<br>• ប័ណ្ណកម្មសិទ្ធ<br>• សំបុត្រកាត់ឈ្មោះផ្ទះ<br>• សំបុត្របង់ថ្លៃ (ភ្លើង ហ្គេស ខ្សែកាប ទូរស័ព្ទ)<br>• វិក្កយប័ត្របង់ពន្ធផ្ទះ<br>• ប័ណ្ណបើកបរ ឬប័ណ្ណដូរអាស័យដ្ឋាន ដែលមានអាស័យដ្ឋានបច្ចុប្បន្ន<br>• លិខិតពី ការិយាល័យសូស្យល់សិខ្យូរីធី ដែលមានអាស័យដ្ឋានបច្ចុប្បន្ន<br>• លិខិតពី ការិយាល័យផ្តល់ប្រាក់ជំនួយ ដែលមានអាស័យដ្ឋានបច្ចុប្បន្ន<br>• គេទទួលលិខិតពី អ្នកចិញ្ចឹមក្មេង/មើលថែក្មេង និងអង្គការ DHS សម្រាប់ការចុះឈ្មោះនៅពេលដែលសិស្សស្ថិតនៅក្រោមការមើលថែរបស់អង្គការ ចិញ្ចឹមក្មេង/មើលថែក្មេង<br>• កិច្ចព្រមព្រៀងជួលផ្ទះដែលមានឈ្មោះ មាតាបិតា/អាណាព្យាបាល និងក្មេង<br>• អត្តសញ្ញាណប័ណ្ណដែលមានសុពលភាពពីក្រសួងយានជំនិះ<br>• វិក្កយប័ត្រពីប័ណ្ណឥណទានថ្មីៗ<br>• ប័ណ្ណចុះបញ្ជីរថយន្តថ្មីៗ<br>• ប័ណ្ណសម្រាប់បោះឆ្នោត ដែលបង្ហាញអាស័យដ្ឋាន**បច្ចុប្បន្ន**<br>• របាយការណ៍គណនីពីធនាគារថ្មីៗ ដែលមានអាស័យដ្ឋានបច្ចុប្បន្ន<br>• លិខិតបង្ហាញចំនួនប្រាក់ពី IRS ឬ ប្រាក់ខែ និងពន្ធ ផ្សេងៗ ដូចជា W2, 1040, 1099<br>• កន្ទុយសែកពីកន្លែងធ្វើការថ្មីៗ បង្ហាញពីអាស័យដ្ឋានបច្ចុប្បន្ន<br>• គេទទួលលិខិតពីកន្លែងជ្រកកោនសម្រាប់សិស្សានុសិស្សដែលគ្មានលំនៅ<br>• ឯកសារលក់ផ្ទះដែលបានចុះហត្ថលេខារួច ព្រមទាំងឯកសារច្បាប់ដើមនៃការកាត់ឈ្មោះផ្ទះក្នុងកំឡុងពេល ៤៥ ថ្ងៃ ចាប់ពីថ្ងៃកាត់ឈ្មោះ<br>***D.1- យុវវ័យ និង ក្រុមគ្រួសារ ដែលគ្មានទីលំនៅ***<br>យុវវ័យដែលគ្មានទីលំនៅ មានសិទ្ធិចុះឈ្មោះចូលរៀនជាបន្ទាន់ ហើយគេមិនតម្រូវឲ្យក្រុមគ្រួសារបញ្ជាក់ពីទីលំនៅ ដើម្បីចុះឈ្មោះចូលរៀនទេ។ និយមន័យនៃ ក្មេង និង យុវវ័យ ដែលគ្មានលំនៅ គឺរួមទាំងក្មេងដែល «រង់ចាំទៅនៅជាមួយអ្នកជួយចិញ្ចឹមក្មេង» និង «យុវវ័យម្នាក់ឯងដែលគ្មានលំនៅ ។» ត្រូវចុះឈ្មោះសិស្សទាំងនេះដោយមិនពន្យាពេល នៅក្រសួងដែលពួកគេកំពុងរស់នៅក្នុងពេលបច្ចុប្បន្ន ឬបន្តការសិក្សារបស់ពួកគេនៅក្រសួងដែលពួកគេបានទៅរៀនពីមុន។ សូមមើលច្បាប់ McKinney-Vento Act, 42 U.S.C. §11431 et seq.<br>*យកល្អ លោកអ្នកត្រូវទាក់ទងទៅសាលា ដើម្បីឲ្យដឹងពីម៉ោងពេលនៃការចុះឈ្មោះ។ |
| ***តើគេតម្រូវឲ្យសិស្សថ្នាក់មត្តេយ្យស្លៀកពាក់ឯកសណ្ឋាន ដែរឬទេ?*** | ព័ត៌មានដែលទាក់ទងនឹង ច្បាប់ឯកសណ្ឋានរបស់ក្រសួងអប់រំ នឹងផ្តល់ជូននៅពេល សម្ភាស/ណែនាំ មាតាបិតា។ សូមពិភាក្សាជាមួយគ្រូរបស់កូនលោកអ្នក នៅពេលនោះ។ |

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

## ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ

| សំណួរដែលគេខ្ញស្សាសួរអំពីថ្នាក់មត្តេយ្យ | |
|---|---|
| **សំណួរ** | **ចម្លើយ** |
| ***តើសិស្សថ្នាក់មត្តេយ្យរៀនពេញថ្ងៃ ឬទេ?*** | ថ្នាក់មត្តេយ្យគឺជាកម្មវិធីពេញមួយថ្ងៃ។ ម៉ោងរៀន ដូចគ្នានឹងសិស្សសាលាទាំងអស់។ |
| ***តើថ្ងៃណា ជាថ្ងៃចុងក្រោយ ដើម្បីចុះឈ្មោះក្មេងឲ្យចូលរៀនថ្នាក់មត្តេយ្យ។*** | ការចុះឈ្មោះក្មេងឲ្យចូលរៀនថ្នាក់មត្តេយ្យ ធ្វើទៅជាបន្ត ដោយគ្មានពេលកំណត់។ |
| ***តើត្រូវធ្វើដូចម្តេច បើសិនជាមាតាបិតាមិនចង់ឲ្យកូនទៅរៀននៅសាលាក្នុងតំបន់?*** | សម្រាប់ឆ្នាំសិក្សាបច្ចុប្បន្ន មាតាបិតា/អាណាព្យាបាល ត្រូវតែចុះឈ្មោះកូនឲ្យចូលរៀននៅសាលាក្នុងតំបន់សិន។ វិធីជ្រើសរើសសាលា គឺសម្រាប់សិស្ស និង ក្រុមគ្រូសារណាដែលចង់ដាក់ពាក្យទៅរៀននៅសាលាដែលនៅក្រៅព្រំដែននៃតំបន់រស់នៅរបស់ពួកគេ សម្រាប់ការទទួលសិស្សឲ្យចូលរៀន ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី១២ នៅឆ្នាំសិក្សាក្រោយ។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមមើលវ៉ិបសៃ៖ www.philasd.org/language/khmer/school-choice. |
| ***តើគេផ្តល់យានជំនិះដល់សិស្សថ្នាក់មត្តេយ្យដែឬទេ?*** | មាតាបិតាត្រូវផ្តល់យានជំនិះសម្រាប់សិស្សថ្នាក់មត្តេយ្យ ដែលនៅឆ្ងាយពីសាលា។ ទោះជាដូច្នេះក៏ដោយ យានជំនិះផ្តល់ឲ្យតែសិស្សថ្នាក់មត្តេយ្យដែលមាន IEP **តែប៉ុណ្ណោះ**។ សូមមើលទំព័រវ៉ិបសៃ សម្រាប់យានជំនិះ ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីការលើកលែងទៅនឹងច្បាប់នេះ។ |
| ***ចុះបើសាលាក្នុងតំបន់ ទទួលសិស្សគ្រប់ចំនួនហើយ?*** | យើងនឹងខិតខំគ្រប់បែបយ៉ាង ដើម្បីចុះឈ្មោះសិស្សថ្នាក់មត្តេយ្យទាំងអស់ ដែលបានសុំចូលរៀននៅសាលាក្នុងតំបន់។ ទោះជាដូច្នេះក៏ដោយ នៅពេលដែលថ្នាក់មត្តេយ្យនៅសាលាក្នុងតំបន់ទទួលសិស្សគ្រប់ចំនួនហើយ ការិយាល័យផ្នែក ចុះឈ្មោះ និង ចាត់តាំសិស្ស ជាកន្លែងដែល សាលា និង មាតាបិតា សុំឲ្យជួយពួកគេជាមួយនឹងវិធីនេះ ទៅតាមករណីនីមួយៗ។ |
| ***តើខ្ញុំអាចទាក់ទងទៅអ្នកណា បើសិនជាខ្ញុំមានសំណួរអំពីកន្លែងចុះឈ្មោះចូលរៀនថ្នាក់ មត្តេយ្យ ឬ ការធ្វើសម្ភាសន៍ពីបទពិសោធន៍ សម្រាប់ការអប់រំមុនថ្នាក់មត្តេយ្យ?*** | ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី ***កន្លែងចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យ ឬការធ្វើសម្ភាសន៍ពីបទពិសោធន៍ សម្រាប់ការអប់រំមុនថ្នាក់មត្តេយ្យ។*** សូមទាក់ទង៖<br>- Doria Mitchell, នាយិកាផ្នែក អក្សរសិល្ប៍ ថ្នាក់មត្តេយ្យដល់ថ្នាក់ទី៣ និង កម្មវិធីពិសេស<br>- Sharai Cunningham, អ្នកជំនួយការផ្នែក អក្សរសិល្ប៍ថ្នាក់មត្តេយ្យដល់ថ្នាក់ទី៣ និងកម្មវិធីពិសេស<br>សូមមើលព័ត៌មានសម្រាប់ទាក់ទងខាងក្រោមនេះ។ |
| ***តើខ្ញុំអាចទាក់ទងទៅអ្នកណា ដើម្បីសួរអំពីការបម្រើទាំងនេះ?*** | **សូមទាក់ទងអ្នកតំណាង នៅការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ ទាំងនេះ៖** |

| | | | |
|---|---|---|---|
| Doria N. Mitchell | នាយិកាផ្នែក អក្សសិល្ប៍ ថ្នាក់មត្តេយ្យដល់ថ្នាក់ទី ៣ និង កម្មវិធីពិសេស | dnmitchell@philasd.org | (២១៥) ៤០០-៥៨១១ |
| Sharai Cunningham | អ្នកជំនួយការផ្នែក អក្សរសិល្ប៍ ថ្នាក់មត្តេយ្យដល់ថ្នាក់ទី៣ និង កម្មវិធីពិសេស | shcunningham@philasd.org | (២១៥) ៤០០-៦១៤០ |
| Tyhira Vorn | សិស្សហាត់ធ្វើការ/ Intern | tvorn@philasd.org | (២១៥) ៤០០-៦៨៦២ |
| Juanita Rodrigues Romu | អ្នកចាត់ចែងកម្មវិធី FAST | jromu@philasd.org | (២១៥) ៤០០-៦៧៦១ |
| Amber Yancy | សិស្សហាត់ធ្វើការ/ Intern | ayancy@philasd.org | (២១៥) ៤០០-៦០៣១ |
| Katherine Bradstreet | P-3 Alignment | kbradstreet@philasd.org | (២១៥) ៤០០-៦៧៦៤ |